ជូនចំពោះក្រុមគ្រួសារនៃសង្កាត់សាលារៀនអូកឡិនដ៍,

ការរៀបចំផែនការរបស់យើងសម្រាប់ឆ្នាំសិក្សា 2020-21 គឺកំពុងឈានចូលក្នុងដំណាក់កាលដ៏សំខាន់មួយ នៅពេលដែលយើងចាប់ផ្តើមរៀបចំផែនការសម្រាប់សេណារីយ៉ូដែលអាចកើតមាន។ យើងខ្ញុំត្រូវការគំនិតយោបល់ និងជំនាញរបស់អ្នក។ នៅខាងក្រោមនេះ មានព័ត៌មានស្តីពីកិច្ចប្រជុំ និងវេទិកាតាមអ៊ិនធឺណិតមួយចំនួន ដែលយើងខ្ញុំនឹងប្រើ ដើម្បីប្រមូលគំនិតយោបល់ និងមតិស្ថាបនា។ ព័ត៌មានអំពីរបៀបថែមទៀតក្នុងការចូលរួម នឹងត្រូវបានចែករំលែកក្នុងពេលឆាប់ៗនេះ។

សេណារីយ៉ូនៃរបៀបដែលយើងនឹងបើកកម្មវិធីរៀនសូត្រពីចម្ងាយ និងកម្មវិធីបង្រៀនដោយផ្ទាល់ នឹងត្រូវបានធ្វើឡើងដោយផ្អែកលើវិស័យចំនួន 4 ដែលចាប់ផ្តើមដោយសុទ្ធតែអក្សរ S៖ Science (វិទ្យាសាស្ត្រ), Safety (សុវត្ថិភាព), Staff Support (ការគាំទ្របុគ្គលិក) និង Student Learning (ការសិក្សារបស់សិស្ស)។ អ្នកបានឃើញរបៀបច្រើន ហើយខុសៗគ្នា ដែលវិបត្តិជំងឺឆ្លងកូវីដបានប៉ះពាល់គ្រប់ផ្នែកខុសៗគ្នានៅក្នុងទីក្រុងរបស់យើង។ អ្នកមានការយល់ដឹង និងបទពិសោធន៍ដែលមិនអាចកាត់ថ្លៃបាន អំពីអ្វីដែលមានប្រសិទ្ធិភាពសម្រាប់សិស្សានុសិស្សរបស់យើង នៅក្នុងបរិយាកាសរៀនសូត្រពីចម្ងាយ ក៏ដូចគ្នាដែរ អ្វីដែលយើងនៅតែត្រូវការដោះស្រាយជាប្រព័ន្ធ ដើម្បីរៀបចំផែនការសម្រាប់ឆ្នាំសិក្សា 2020-21។

យើងកំពុងបង្កើតក្រុមការងារជាក់លាក់ និងកិច្ចការប្រជុំផ្សេងៗទៀត ដើម្បីចូលរួមជាមួយនឹងបុគ្គលិកដែលមានសញ្ញាបត្រ (ដូចជា៖ គ្រូបង្រៀន, គិលានុបដ្ឋាយិកា, នាយកសាលា) និងបុគ្គលិកដែលពុំត្រូវការសញ្ញាបត្រ (ដូចជា៖ អ្នកជំនួយការអ្នកអប់រំ, អ្នកជំនួយការផ្នែករដ្ឋបាល) ក្នុងកិច្ចសហការជាមួយសហជីពការងាររបស់យើង។ យើងខ្ញុំសូមថ្លែងអំណរអរគុណមនុស្សគ្រប់គ្នា ដែលបានចូលរួមជួយជាគំនិតយោបល់យ៉ាងសកម្មសម្រាប់ឆ្នាំក្រោយ ហើយសូមស្វាគមន៍នូវមតិស្ថាបនាទាំងអស់ ខណៈដែលយើងរៀបចំរចនាសម្ព័ន្ធបញ្ចូលជាផ្លូវការទាំងនេះថែមទៀត ជាមួយនឹងដៃគូការងាររបស់យើង។

## ឱកាសជួបប្រជុំគ្នាតាមអ៊ិនធឺណិតសម្រាប់ក្រុមគ្រួសារ និងប្រជាសហគមន៍

មានឱកាសពីរសម្រាប់ក្រុមគ្រួសារ និងប្រជាសហគមន៍ នៅសប្តាហ៍ក្រោយ ដើម្បីចាប់ផ្តើមចូលរួមក្នុងការងារនេះ៖

- កិច្ចប្រជុំនៅសាលាក្រុងសម្រាប់ប្រជាសហគមន៍ OUSD ធ្វើនៅថ្ងៃទី 1 មិថុនា ម៉ោង 6:30 - 8:30 យប់ តំណធ្វើការឆ្លើយតប
- កិច្ចប្រជុំសម្រាប់ក្រុមគ្រួសារសិស្សអ្នករៀនភាសាអង់គ្លេស ធ្វើនៅថ្ងៃទី 4 មិថុនា ម៉ោង 5:30-7 យប់ (សូមចុចទីនេះដើម្បីចូលរួម; លេខសម្ងាត់ 141598)

សូមចុចលើតំណនានានៅខាងលើ ដើម្បីឆ្លើយតបចំពោះកិច្ចប្រជុំទាំងនេះ។ យើងខ្ញុំសង្ឃឹមថា នឹងបានស្តាប់ឮអំពីអ្វីខ្លះដែលអ្នកបានរៀនសូត្រពីបទពិសោធន៍របស់អ្នក ក្នុងរយៈពេលពីរខែកន្លងមកនេះ ពិភាក្សាគ្នាអំពីវិធីសាស្ត្ររបស់សង្កាត់ ដើម្បីរៀបចំផែនការសម្រាប់ឆ្នាំក្រោយ និងទទួលបាននូវគំនិតយោបល់ ដើម្បីកំណត់អាទិភាពរបស់សង្កាត់សម្រាប់ឆ្នាំសិក្សា 2020-21។

### ចែករំលែកគំនិតយោបល់របស់អ្នកតាមអ៊ិនធឺណិតតាមរយៈកម្មវិធីផ្លោះប្តូរគំនិតគ្នា។

ប្រសិនបើអ្នកមិនអាចចូលរួមក្នុងកិច្ចប្រជុំទាំងនេះទេ ឬមានគំនិតខ្លះថែមទៀត ដែលអ្នកចង់ចែករំលែកបន្ថែមនោះ សូមចូលរួមនៅក្នុងកម្មវិធីផ្លោះប្តូរគំនិតយោបល់តាមអ៊ិនធឺណិត។

1. **កម្មវិធីរៀនសូត្រពីចម្ងាយ៖** តើអ្វីខ្លះដំណើរការបានល្អ ហើយអ្វីខ្លះទៅដែលយើងអាចកែលំអ?
   ក. តំណទៅកាន់កម្មវិធីផ្លោះប្តូរ៖ សូមចុចទីនេះ ឬគេហទំព័រ https://my.thoughtexchange.com/877298011
2. **ឆ្នាំក្រោយ៖** តើអ្នកត្រូវការអ្វីខ្លះ ដើម្បីឱ្យមានអារម្មណ៍ថា អ្នកមានសុវត្ថិភាព និងមានការគាំទ្រ នៅពេលដែលយើងពិចារណាលើផែនការសម្រាប់ការបង្រៀនដោយផ្ទាល់?
   a. តំណទៅកាន់កម្មវិធីផ្លោះប្តូរ៖ សូមចុចទីនេះ ឬគេហទំព័រ https://my.thoughtexchange.com/921220825

ដើម្បីឆ្លើយសំណួរទាំងនេះ និងដើម្បីមើលចម្លើយរបស់ប្រជាសហគមន៍ដទៃទៀតនោះ សូមចូលទៅកាន់តំណផ្លោះប្តូរគំនិតគ្នាដែលបានដាក់ជូនខាងលើ ហើយផ្តល់គំនិតរបស់អ្នកនៅទីនោះ ហើយបន្ទាប់មក សូមចំណាយពេលខ្លះ ដើម្បីឱ្យតម្លៃចាប់ពីផ្កាយ

1 ដល់ផ្កាយ 5 ចំពោះគំនិតយោបល់នីមួយៗដែលក្នុងនោះមានចំនួនប្រហែលពី 20-30 គំនិត ដែលអ្នកចូលរួមផ្សេងៗទៀតបានលើកឡើង។

នេះជួយឱ្យយើងដឹងថាតើមានបញ្ហាអ្វីខ្លះដែលគួរឱ្យយកចិត្តទុកដាក់លើ ជាពិសេសនៅក្នុងសហគមន៍របស់យើងនេះតែម្តង។

យើងខ្ញុំកោតស្ញប់ស្ញែងចំពោះក្រុមគ្រួសារ លោកគ្រូ-អ្នកគ្រូ បុគ្គលិក និងប្រជាសហគមន៍របស់យើង ដែលបានចំណាយអស់រយៈពេលជាងពីរខែកន្លងមកនេះ ក្នុងការគាំទ្រសិស្ស និងបន្តការរៀនសូត្រនៅក្នុងបរិបទធំធេងនៃភាពមិនប្រាកដប្រជានេះ។ សូមថ្លែងអំណរអរគុណយ៉ាងជ្រាលជ្រៅចំពោះអ្វីៗទាំងអស់ដែលអ្នកកំពុងធ្វើរាល់ថ្ងៃ ដើម្បីជួយរក្សាឱ្យសិស្សមានសុខសុវត្ថិភាព មានការគាំទ្រ និងការចូលរួមក្នុងការសិក្សា។

ហើយជាការពិតណាស់ ប្រសិនបើអ្នកមានសំណួរ ឬចង់ផ្តល់គំនិតយោបល់ ដាក់ចូលក្នុងផែនការឆ្នាំក្រោយនោះ សូមទំនាក់ទំនងមកចុះតាមរយៈអ៊ីមែល ousd-covid19-response-team@googlegroups.com នេះ។

ដោយក្តីគោរពស្មោះពីនាងខ្ញុំ,

SailajaSuresh